ទីស្តីការក្រសួងយុត្តិធម៌

លេខ ៧២៧ រប ៦០១៦-៩៤

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

លោកប្រធានតុលាការ គ្រប់ខេត្ត ក្រុង

ព្រះរាជអជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង

សូមជ្រាប។

**កម្មវត្ថុ:** -អំពីការសុំបន្ធូរបន្ថយទោស និងលើកលែងទោស ឲ្យទណ្ឌិត ក្នុងឱកាសបុណ្យពិសាខបូជា ។

**យោង:** -លិខិតលេខ២៣១ រ.វ. ចុះថ្ងៃទី០៥-០៥-៩៤ របស់អគ្គនាយកដ្ឋានព្រះបរមរាជវាំង ។

-លិខិតលេខ៦០៣ ខុ.ទ្ធ-៩៤ របស់ខុទ្ទកាល័យ រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំសូមជម្រាបថាតាមព្រះរាជឱង្ការព្រះករុណាជាម្ចាស់ជីវិតលើត្បូង នាអង្គប្រជាសវនាការលើកទី៤ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩៤ នៅប្រាសាទភោជនីយ៍ ព្រះករុណាព្រះអង្គទ្រង់មានព្រះរាជយោបល់យកថ្ងៃបុណ្យពិសាខបូជា ជាថ្ងៃសម្រាប់បន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិតបន្ថែមទៀត។ ។ ដូច្នេះការស្នើរសុំបន្ធូរបន្ថយទោសនិងលើកលែងទោសត្រូវធ្វើ ៣ ដងក្នុង ១ ឆ្នាំ គឺ ៖

-នៅពេលព្រះរាជពិធីបុណ្យតាំងតុ

-នៅពេលបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ

-នៅពេលបុណ្យពិសាខបូជា

ឯទម្រង់បែបបទត្រូវធ្វើតាមសេចក្តីណែនាំ នៃទម្រង់បែបបទដែលក្រសួងបានណែនាំពីមុនមកគ្មានការកែប្រែទេ ។

អាស្រ័យហេតុនេះ សូមលោកប្រធានតុលាការ និងព្រះរាជអាជ្ញាតុលាការខេត្ត ក្រុង ធ្វើសំណើនេះឡើងដោយយកចិត្តទុកដាក់ពិនិត្យពីឈ្មោះទណ្ឌិត ថ្ងៃ ខែ ឆ្នាំ ចាប់ខ្លួន នឹងលេខ ថ្ងៃ ខែ ឆ្នាំ សាលក្រម ឱ្យបានត្រឹមត្រូវដោយបញ្ជូនភ្ជាប់មកតាមសំណើនូវសាលក្រមទាំងនោះផង ។

ភ្ជាប់មកជាមួយនូវះ

-សេចក្តីចតចម្លងលិខិតអគ្គនាយកដ្ឋានព្រះបរមរាជវាំង.............០១ ច្បាប់

ធ្វើនៅភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

ចម្លងជូន

-ក្រសួងមហាផ្ទៃ

-អភិបាលខេត្ត ក្រុង

-ប្រធានតុលាការកំពូល

-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-ប្រធានសាលាឧទ្ធរណ៍

-អគ្គព្រះរាជអាជ្ញាររបស់លាឧទ្ធរណ៍

-ប្រធានតុលាការយោធ